ខុមហ្វ្រែល COMFREL

និកហ្វិច

NICFEC

CHRAC

CAMBODIAN HUMAN RIGHTS ACTION COMMITTEE

**គណៈកម្មាធិការខុមហ្វ្រែល ~ គណៈកម្មាធិការនិកហ្វិច ~ គណៈកម្មាធិការប្រព្រឹត្តិកម្ម**
**នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា**

# សេចក្តីថ្លែងការណ៍រួម

## ស្តីពី

## ការព្រួយបារម្ភជុំវិញបរិយាកាសបំភិតបំភ័យនយោបាយ និងការរារាំងសកម្មភាពនយោបាយ មុនដំណាក់កាលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ ២០០៨

**គណៈកម្មាធិការខុមហ្វ្រែល គណៈកម្មាធិការនិកហ្វិច និង គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា** មានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការបន្តមានឥទ្ធិពលនយោបាយ ទៅលើប្រព័ន្ធយុត្តិធម៌ តុលាការ និងកងកម្លាំងប្រដាប់អាវុធ អនុវត្តច្បាប់[១] ជាពិសេស ព្រឹត្តិការណ៍ថ្មីៗនេះ ទាក់ទងនឹងការចាប់ឃុំខ្លួន ការស្វែងរកចាប់ខ្លួន ការប្រើអំពើហិង្សាមកលើសកម្មជនគណបក្សនយោបាយ និងការបន្តការរារាំងការធ្វើសកម្មភាពរបស់គណបក្សនយោ-បាយមួយចំនួន។ ករណីទាំងនេះ ភាគច្រើនបានកើតនៅតែក្នុងទីកន្លែង(ខេត្ត/ក្រុង)ដដែលៗ ដូចជា ទីក្រុងភ្នំពេញ ប៉ៃលិន ខេត្តកំពង់ធំ តាកែវ កំពង់ឆ្នាំង ហើយដែលបានធ្វើឱ្យប៉ះពាល់ដល់បរិយាកាសបោះឆ្នោតមួយ ប្រកបដោយលក្ខណៈសេរី និងយុត្តិធម៌។

ការចាប់ខ្លួនដោយមិនបានបង្ហាញដីកា និងមិនមានការស៊ើបអង្កេតឱ្យបានច្បាស់លាស់ ទៅលើសមាជិកសកម្មជនគណបក្សនយោបាយ[២] បានបង្កឱ្យមានបរិយាកាសភ័យខ្លាច បំបាក់ស្មារតីដល់សកម្មជនគណបក្សមិនកាន់អំណាចនានា។ ទន្ទឹមនឹងនេះ មានការសង្ស័យអំពីការផ្លាស់ប្តូរចម្លើយរបស់ជនរងគ្រោះ អ្នកស្រី ទឹម ណាន ដែលបានជួបជាមួយអង្គការសិទ្ធិមនុស្សលីកាដូ និងមន្ត្រីនៃការិយាល័យប្រចាំប្រទេសកម្ពុជា នៃឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិ

---

[១] ធ្លាប់មានការអះអាងនៅក្នុងរបាយការណ៍សិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា របស់សមាគមអាដហុក និងអង្គការលីកាដូ *"យុត្តិធម៌គ្មានភាពប្រាកដនិយម"* ខែ ធ្នូ ឆ្នាំ ២០០៧។

[២] យោងតាមរបាយការណ៍របស់គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជាៈ លោក ទួត សារ៉ន មេឃុំពង្រ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ត្រូវបានក្រុមប៉ូលីសដែលដឹកនាំ ដោយលោកអធិការស្រុកបារាយណ៍ ចាប់ខ្លួននៅតាមផ្លូវម៉ុផ្សារទួលគ្រើល ស្រុកបារាយណ៍ ដោយពុំមានបង្ហាញដីកានាំខ្លួននោះទេ។

មនុស្ស និងចម្លើយនាពេលក្រោយមក។ នៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៨ នៅស្នាក់ការអង្គការលីកាដូ អ្នកស្រី ទីម ណេន **មិនបានប្ដឹងអំពីការឃុំឃាំងលើរូបអ្នកស្រីអ្វីទេ** ផ្ទុយទៅវិញ អ្នកស្រី បានមក**ពឹងអង្គការលីកាដូឱ្យជួយការពារសុវត្ថិភាព រូបអ្នកស្រី និងក្រុមគ្រួសារ** ពីករណីដែលអ្នកស្រីបានចេញពីគណបក្សសមរង្ស៊ី ទៅចូលរួមជាមួយគណបក្សប្រជាជនកម្ពុជា ហើយក្រោយមក អ្នកស្រីចង់ត្រលប់មកគណបក្សសមរង្ស៊ីវិញ។ ប៉ុន្តែក្រោយមក អ្នកស្រីបែរជាឆ្លើយថា **អ្នកស្រីភ័យខ្លាចគណបក្សសមរង្ស៊ី សម្លាប់អ្នកស្រីទៅវិញ**[៣]។

យោងតាមការស៊ើបអង្កេតរបស់គណៈកម្មាធិការប្រព្រឹត្តកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា បានរកឃើញថា អ្នកស្រី ទីម ណេន **ពុំមានការបាត់បង់នូវសិទ្ធិសេរីភាពរបស់ខ្លួន** ក្នុងការទំនាក់ទំនងជាមួយមិត្តភក្តិ និងក្រុមគ្រួសារនោះទេ ហើយពុំមានចំណុចណាមួយដែលជាធាតុផ្សំ បញ្ជាក់ថា **អ្នកស្រី ត្រូវបានអ្នកណាម្នាក់ ធ្វើការបង្ខាំង ឬឃាត់ខ្លួនអ្នកស្រីឡើយ**។

**មានការបង្កការរំខាន និងរារាំងដល់សកម្មភាពគណបក្សនយោបាយ** រួមមានគណបក្សសមរង្ស៊ី គណបក្សសិទ្ធិមនុស្ស គណបក្សនរោត្តមរណឫទ្ធិ គណបក្សហ៊្វុនស៊ិនប៉ិច តាំងពីបង្ក**ការរំខានការប្រជុំ** រហូតដល់ករណីខ្លះ បានប្រើការបង្ក្រាបពីសំណាក់អាជ្ញាធរមូលដ្ឋាន ក្នុង**ការទម្លាក់ស្លាកគណបក្ស** ឬការបញ្ឈប់ការប្រជុំនានា។ ករណីជាក់ស្តែង **មានអំពើហិង្សាក្នុងការទម្លាក់ស្លាកគណបក្សសមរង្ស៊ី** រហូតឈានដល់ការបង្ករបួសស្នាមទៅលើអ្នកតំណាងរាស្ត្រមណ្ឌលភ្នំពេញ ឯ.ឧ ហូ វ៉ាន់ កាលពីថ្ងៃ ទី ២២ ខែ មីនា ឆ្នាំ ២០០៨។ ករណីទម្លាក់ស្លាកគណបក្សសមរង្ស៊ីនេះ ក៏បានកើតឡើងនៅក្នុងក្រុងប៉ៃលិនផងដែរ។ ចំណែកឯស្លាកគណបក្សនរោត្តមរណឫទ្ធិ នៅក្នុងខេត្តបន្ទាយមានជ័យ ក៏រងការទម្លាក់ផងដែរ។ ជាសរុបករណីទម្លាក់ស្លាកគណបក្សនយោបាយគិតរហូតមកដល់ពេលនេះ មានប្រមាណយ៉ាងតិច ២០ ករណីហើយដែលយើងបានទទួលព័តិមាន។ ករណីទាំងនេះ ដែលបានកើតមានចំពោះគណបក្សមិនកាន់អំណាច មិនត្រូវបានដោះស្រាយដោយយុត្តិធម៌នៅឡើយ។

នៅសល់រយៈពេលមិនដល់មួយខែទៀតទេ ដែលកាលបរិច្ឆេទចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ប៉ុន្តែករណីសម្តេចក្រុមព្រះ **នៅពុំទាន់មានដំណោះស្រាយណាមួយនៅឡើយទេ**។ បញ្ហានេះ អាចចាត់ថា ជាការប្រកួតប្រជែងបោះឆ្នោត **ប្រព្រឹត្តទៅដោយពុំស្មើភាព** ដោយមេដឹកនាំ និងទំនងជាបេក្ខជនមានសក្តានុពលមួយរូប មិនបាន ចូលរួមប្រកួតប្រជែង ក្នុងការបោះឆ្នោតនាពេលខាងមុខនេះទេ។

**អង្គការសង្គមស៊ីវិល វាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងអាជ្ញាធរមានសមត្ថកិច្ចដែលបានធ្វើឱ្យបរិយាកាសមុនការបោះឆ្នោតឆ្នាំ ២០០៨ គ្មានអំពើឃាតកម្ម និងអំពើហិង្សាខាងនយោបាយធ្ងន់ធ្ងរទៅលើអ្នកនយោបាយ**។ ទោះបីយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាល និងអាជ្ញាធរមានសមត្ថកិច្ច ត្រូវខិតខំបន្ថែមទៀត ដើម្បីបញ្ឈប់ការ

---

[៣] យោងរបាយការណ៍អង្គការលីកាដូ និងសារព័តិមាន ឌឹ ឃេមបូឌា ដេលី ថ្ងៃច័ន្ទ ទី ២៤ ខែ មីនា ឆ្នាំ ២០០៨ ទំព័រទី ៥។

ចាប់ខ្លួន បំភិតបំភ័យ និងអំពើហិង្សាទៅលើសកម្មជនគណបក្សនយោបាយ និងអ្នកនយោបាយ ។ រាជរដ្ឋាភិបាល អាជ្ញាធរមានសមត្ថកិច្ច និងភាគីពាក់ព័ន្ធនានា ត្រូវខិតខំដោះស្រាយបញ្ហានានា ដ៏មានប្រសិទ្ធភាព ក្នុងការធានាឱ្យមានបរិយាកាសបោះឆ្នោតមួយ ប្រកបដោយលក្ខណៈសេរី និងយុត្តិធម៌ និងដើម្បីបង្កឱ្យអ្នកនយោបាយ និងមេដឹកនាំគណបក្សផ្សេងៗទៀត (ដូចករណីសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ) បានចូលរួមប្រកួតប្រជែងការបោះឆ្នោត មានលក្ខណៈស្មើភាព និងគ្មានការភ័យខ្លាច ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០០៨*

**គណៈកម្មាធិការខុមហ្វ្រែល ~ គណៈកម្មាធិការនិកហ្វិច ~ គណៈកម្មាធិការប្រព្រឹត្តកម្ម**

*សំរាប់ព័ត៌មានផ្សេងៗសូមទំនាក់ទំនង :*

| | | |
|---|---|---|
| ១. លោក **គល់ បញ្ញា** | នាយកប្រតិបត្តិ គណៈកម្មាធិការខុមហ្វ្រែល | ទូរស័ព្ទ : ០១២ ៩៤២ ០១៧ |
| ២. លោក **ហង្ស ពុទ្ធា** | នាយកប្រតិបត្តិ គណៈកម្មាធិការនិកហ្វិច | ទូរស័ព្ទ : ០១២ ៩៥៩ ៦៦៦ |
| ៣. លោក **សួន សារ៉េត** | លេខាធិការប្រតិបត្តិគណៈកម្មាធិការប្រព្រឹត្តិកម្ម | ទូរស័ព្ទ : ០១២ ៨៣០ ៤២២ |